# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៧ អនក្រ.បក
### ស្ដីពីការកំណត់ប្រាក់បេសកកម្មក្នុងប្រទេស

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សំរេច

មាត្រា ១ .- របបឧបត្ថម្ភជីវភាពចំណាយសំរាប់ផ្ដល់ជូនមន្ត្រីរាជការបំពេញការងារបេសកកម្ម ក្នុងប្រទេសត្រូវបានកំណត់ដូចខាងក្រោម ៖

ក-បេសកកម្មក្នុងខេត្ត

-ឧបត្ថម្ភរបបបេសកកម្មចំនួន ៨.០០០៛០០ ម្នាក់ ក្នុង១ថ្ងៃ

-សោហ៊ុយចំណាយផ្សេងៗ ( ធ្វើដំណើរ ហូបចុក ស្នាក់នៅ ) គ្មាន

ខ-បេសកកម្មឆ្លងខេត្ត

-ឧបត្ថម្ភរបបបេសកកម្មចំនួន ៨.០០០៛០០ ម្នាក់ ក្នុង ១ថ្ងៃ

-ឧបត្ថម្ភប្រាក់ហូបចុកចំនួន ១៥.០០០៛០០ ម្នាក់ ក្នុង១ថ្ងៃ

-ឧបត្ថម្ភប្រាក់ស្នាក់នៅចំនួន ៣៨.០០០៛០០ ម្នាក់ ក្នុង១ថ្ងៃ

មាត្រា ២ ._ ការទូទាត់ ៖

-ប្រាក់បេសកកម្មកំណត់ខ្ពស់បំផុតត្រឹម ១០ ថ្ងៃ លើកលែងមានករណីពិសេសដែលទាក់ទងនឹងការងារបច្ចេកទេសតែមិនត្រូវអោយលើសពី ១៥ ថ្ងៃ ។ បើលើសពីនេះចាំបាច់ត្រូវមានបញ្ជាបេសកកម្មបន្តតែក៏មិនអោយលើសពី ២០ ថ្ងៃក្នុង ១ខែ ។

-ប្រាក់ហូបចុក គិតតាមចំនួនថ្ងៃការងារ

-ប្រាក់ស្នាក់នៅដោះស្រាយជូនទៅតាមវិក្កយបត្រជាក់ស្តែង និងមានការបញ្ជាក់ត្រឹមត្រូវ ។ បើជារូបិយប័ណ្ណអន្តរជាតិ ច្រើនបំផុតត្រឹម ១០ ដុល្លារអាមេរិក ក្នុងម្នាក់-ថ្ងៃ ។

-ប្រាក់ហូបចុក និងស្នាក់នៅ ត្រូវកត់ត្រាក្នុងខ្ទង់ចំណាយតែមួយគឺ ជំពូក ១១-០២-០១-០៣ ។

-មធ្យោបាយធ្វើដំណើរ ( ក្នុងករណីគ្មានមធ្យោបាយរបស់រដ្ឋ ) ដោះស្រាយជូនតាមវិក្កយបត្រជាក់ស្តែង និងមានការបញ្ជាក់ត្រឹមត្រូវ ។

-រាល់ការទូទាត់ត្រូវអនុវត្តជាប្រាក់រៀល បើទោះបីមានមុខសញ្ញាចំណាយខ្លះជារូបិយប័ណ្ណបរទេសក៏ដោយ ។

មាត្រា ៣ ._ រាល់ខ្លឹមសារកំណត់ទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខា ធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★ ★

**អនុក្រឹត្យលេខ ០៨ អនក្រ.បក**

**ស្តីពីការបង្កើតក្រុមអ្នកច្បាប់ និង នាយកដ្ឋាន**

**ទំនាក់ទំនងអន្តរជាតិ និង អាស៊ាន ចំណុះក្រសួងមហាផ្ទៃ**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី